# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១២

# ជប៉ុនផ្តល់ ៩៧,៥៩៦ ដុល្លារអាមេរិក សម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពទំនប់ព្រៃគ្រើលក្នុងខេត្តព្រៃវែង



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណិ)រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ៩៧,៥៩៦ ដុល្លាអាមេរិក ដល់មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែងសម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពទំនប់ព្រៃគ្រើលក្នុងខេត្តព្រៃវែង ។កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តម គូរ៉ូគី ម៉ាសាហ៊ីរ៉ូ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ជុំ សុភី ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែងនៅស្ថានទូតជប៉ុន។



ជាមួយនឹងជំនួយនេះ ប្រព័ន្ធស្រោចស្រពទំនប់ព្រៃគ្រើល នឹងត្រូវបានជួសជុលដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្តព្រៃវែង។គម្រោងនេះរួមបញ្ចូលការជួសជុលទំនប់អាងទឹកប្រវែង២,១០០ម៉ែត្រ ការជួសជុលសំណង់លូ និងការសាងសង់សំណង់ទ្វារទឹក និងសំណង់លូ។ យើងរំពឹងថាវានឹងសម្រួលដល់ការងារស្រោចស្រពរបស់ប្រជាកសិករ ប្រមាណ១,២៧៥គ្រួសារនៅក្នុងតំបន់។ដោយមានជំនួយផ្នែកបច្ចេកទេសពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រៃវែងប្រជាសហគមន៍នឹងថែទាំប្រព័ន្ធស្រោចស្រពនេះឲ្យមានសភាពល្អជានិច្ច។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណេ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជាភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាល ជប៉ុនបានផ្តល់ថវិកាជាង ៤៨.១លាន ដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាននិងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៧៨គម្រោងនៅទូទាំងប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*